**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលខេត្តក្រចេះ**

លេខ០៣៧២/១៦ រ.ស.ជ.ណ

ថ្ងៃទី.០៥....ខែ កញ្ញា ឆ្នាំ ២០១៦

## សេចក្តីជូនដំណឹង

## ស្តីពី

## ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការលទ្ធកម្មគម្រោងឃុំ សង្កាត់ឆ្នាំ២០១៧

គណៈអភិបាលនៃខេត្តក្រចេះនឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៧ សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧ ។អ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការមានសិទ្ធិដាក់សំណើដេញថ្លៃគ្រប់គម្រោងមូលនិធិឃុំសង្កាត់ទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

អ្នកទទួលការត្រូវបានបែងចែកជា០៣ប្រភេទ ៖

- ប្រភេទទី១ ៖ អ្នកទទួលការសំណង់ទូទៅ(ការងារសំណង់អគារ និងការងារបេតុង... ។ល ។)
- ប្រភេទទី២ ៖ អ្នកទទួលការការងារដី(ប្រឡាយ ទំនប់ ផ្លូវដីស ផ្លូវក្រួសក្រហម ... ។ល ។)
- ប្រភេទទី៣ ៖ អ្នកទទួលការឯកទេស (អ្នកទទួលការដែលមានឧបករណ៍ និងជំនាញបច្ចេកទេសសម្រាប់ការងារ ពិសេស ឧទាហរណ៍ អណ្តូងស្នប់... ។ល ។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស និងសម្ភារៈបរិក្ខារគ្រប់គ្រាន់ ដូចមានបរិយាយនៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំហើយត្រូវមានបទពិសោធន៍អនុវត្តគម្រោងទាក់ទង នឹងប្រភេទនីមួយៗដែលបានស្នើសុំយ៉ាងតិច០២ក្នុងអំឡុងពេល៥ឆ្នាំចុងក្រោយ ។អនុគណៈកម្មការបុរេលក្ខណសម្បត្តិនឹងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ និងវាយតម្លៃសមត្ថភាពបច្ចេកទេសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចមានបរិយាយនៅក្នុងពាក្យសុំចុះបញ្ជី ព្រមទាំងពិនិត្យមើលគុណភាពការងារ ភាពស្មោះត្រង់ ការអនុវត្តការងារទាន់ពេលវេលា និងកិច្ចសហប្រតិបត្តិការ របស់អ្នកទទួលការជាមួយម្ចាស់គម្រោង ដោយផ្អែកលើកំណត់ត្រាកន្លងមក ។លទ្ធផលនៃការវាយតម្លៃនេះ អនុគណៈកម្មការ បុរេលក្ខណសម្បត្តិ នឹងដាក់ជូនអភិបាលរាជធានី ខេត្ត ដើម្បីពិនិត្យនិងសម្រេច ។ អ្នកទទួលការទាំងឡាយណា ដែលត្រូវបានរកឃើញថាមានការពាក់ព័ន្ធនឹងការឃុបឃិតសុំគ្រលំគ្នា ការក្លែងបន្លំ និងអំពើពុករលួយ ហើយចាប់ពីពេលដែលត្រូវបានដកសិទ្ធិជាផ្លូវការ អ្នកទទួលការនោះ នឹងមិនត្រូវបានពិចារណាក្នុងការបញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះអ្នកទទួលការឡើយ ។

អាស្រ័យហេតុនេះ បើអ្នកទទួលការមានបំណងចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ សូមរួសរាន់មកដាក់ពាក្យសុំចុះ ឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការនៅ ទីចាត់ការផែនការនិងវិនិយោគនៃសាលារាជធានី ខេត្ត ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង១៧គត់ ។ ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឆ្នាំកន្លងមក ក៏ត្រូវដាក់ពាក្យ សុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការជាថ្មីឡើងវិញដែរ ។អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការនៅទីចាត់ការផែនការនិងវិនិយោគសាលាខេត្តក្រចេះដោយឥតបង់ថ្លៃ ឬអាចទាញយកពីក្នុងគេហទំព័ររបស់ គ.ជ.អ.ប ។

*ចម្លងជូន:*

*- ឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្ត*

*"ដើម្បីជូនជ្រាប"*

*-ឯកសារ-កាលប្បវត្តិ*

**អភិបាលខេត្ត**

**ស៊ រ ចំរុង**